DOCUMENT RECEIVED/DOCUMENT REÇU
(Date of receipt/date de reception):
(Time/Heure): 21-Jul-2009, 10:17
Chanthan Phok

CERTIFIED COPY/COPIE CERTIFIÉE CONFORME
(Certified Date /Date de certification):
21-Jul-2009
Chanthan Phok

Declassified to Public
06 September 2012

នៅខែកក្កដា ឆ្នាំ១៩៧៣ ឪពុករបស់ខ្ញុំឈ្មោះ Miles Hamill ដែលជាវរៈសេនីយ៍ឯកសេអ៊ីអានោះ បាននិយាយប្រាប់ខ្ញុំថា ដោយសារតែមានការកសាងកងទ័ពជើងទឹកសូវៀតកាលពីបីបួនឆ្នាំមុននោះ សេអ៊ីអាមានផែនការណ៍ដាក់ការត្រួតត្រាលើផ្លូវទឹកសំខាន់ៗមួយចំនួននៅជុំវិញពិភពលោក។ ជាមួយនិងការកសាងកងនាវាមហាសមុទ្រឥណ្ឌារបស់សូវៀតនោះ ឪពុករបស់ខ្ញុំបានគិតថា តាមយុទ្ធសាស្ត្រជ្រោយម៉ាឡាកានឹងក្លាយជាជ្រោយដែលសំខាន់ណាស់ ហេតុនេះគាត់បានរៀបរាប់ប្រាប់ខ្ញុំពីផែនការសម្រាប់ជ្រោយម៉ាឡាការបស់សេអ៊ីអា។

សម្រាប់សេអ៊ីអា តាមវិធីសាស្ត្រធម្មតានៃការសូកប៉ាន់ចំពោះរដ្ឋមន្ត្រីរដ្ឋាភិបាលម៉ាឡេស៊ីមួយចំនួន សហរដ្ឋអាមេរិកនឹងត្រូវបានដាក់បញ្ចូលនូវជ្រោយម៉ាឡាកា និងកំពង់ផែខ្លាង (Port Khang) ធ្វើជាកន្លែងពីរដើម្បីបង្កើតបន្ទាយកងទ័ពជើងទឹកនិងកងទ័ពជើងគោក។ បន្ទាយទាំងនេះនឹងត្រូវបានបង្កើតឡើង រីឯទីកន្លែងកាំភ្លើងធុនធ្ងន់នឹងត្រូវបានបង្កើតឡើងផងដែរ។ បន្ទាយទាំងនេះនឹងជាកន្លែងដែលមើលឃើញជ្រោយម៉ាឡាកា រួចហើយនឹងគ្រប់គ្រងការធ្វើចរាចរទាំងអស់នៅក្នុងជ្រោយនោះ។ បន្ទាយកងទ័ពជើងទឹកនឹងត្រូវបានបង្កើតឡើងនៅកំពង់ផែខ្លាង។ កប៉ាល់ទាំងនេះនឹងទទួលខុសត្រូវខាងឃាមល្បាតជ្រោយម៉ាឡាកាទាំងអស់ចាប់ពីប្រទេសសិង្ហបុរីទៅកាន់រដ្ឋប៉េណាង (Penang) [ចន្លោះរវាងឧបទ្វីបម៉ាឡេស៊ីនិងកោះស៊ូម៉ាត្រាប្រទេសឥណ្ឌូនេស៊ី]។ ដើម្បីបំពេញបាននូវការគ្របដណ្តប់របស់អាមេរិកលើតំបន់នេះ ការគ្រប់គ្រងដែលពោរពេញដោយអំណាចនឹងត្រូវបង្កើតឡើង សូម្បីតែនៅផ្នែកខាងចុងជ្រោយក៏ដោយ។ ទាំងអស់នេះនឹងត្រូវបានដាក់ឈ្មោះដោយកងទ័ព ហើយនឹងរក្សានូវការរាប់ជាដើម នូវចំនួនកប៉ាល់ទាំងអស់ដែលឆ្លងកាត់តាមជ្រោយនេះ។

ការគ្របដណ្តប់លើជ្រោយម៉ាឡាកាតាមផ្លូវអាកាស តាមផ្លូវទឹក និងតាមផ្លូវគោក តាមរយៈកងកម្លាំងមូលដ្ឋានដ៏ពេញលេញនេះ នឹងធានាបាននូវការត្រួតត្រាទៅលើផ្លូវទឹកនេះដោយពួកអាមេរិក។

ផែនការនេះនឹងធ្វើប្រតិបត្តិការ ស្របតាមលក្ខខ័ណ្ឌមួយក្នុងចំណោមលក្ខខ័ណ្ឌចំនួនពីរ: ទីមួយ កងនាវាសូវៀតនៅក្នុងមហាសមុទ្រឥណ្ឌាមិនមានចំនួនលើសពីកងនាវាដែលជាសម្ព័ន្ធមិត្តនឹងគ្នា ក្នុងចំនួនច្រើន ឬក៏ ទីពីរ ប្រសិនបើកប៉ាល់សូវៀតចាប់ផ្តើមរាំងស្ទះដោយវិធីណាជាមួយកងនាវាអ្នកជំនួញ ឬកងនាវាជើងទឹករបស់ប្រទេសណាមួយនៅក្នុងមហាសមុទ្រឥណ្ឌានោះ។

នៅពេលដែលផែនការនេះត្រូវបានប្រតិបត្តិ គឺត្រូវនឹងពេលវេលាដែលបានកំណត់ហើយ។ គណៈបក្សជាតិ បានឈ្នះការបោះឆ្នោតទាំងនេះដោយភាគច្រើនលើសលុប នៅពេលដែលគណបក្សការងារនៅមានបញ្ហាជាមួយនឹងចំណាប់អារម្មណ៍ជាសាធារណៈនៅឡើយ។

សេអ៊ីអាបានប្រើប្រាស់វិធីសាស្ត្រនៃការគម្រាមរកប្រយោជន៍ និងអំពើពុករលួយដូចគ្នាទាំងនេះនៅជុំវិញពិភពលោក។

សេអ៊ីអាមានការពាក់ព័ន្ធនឹងកោះតៃវ៉ាន់តាំងពីឆ្នាំ១៩៥០មកម្ល៉េះ។ ក្នុងអំឡុងពេលនោះ ពួកគេបានកសាងកម្លាំងទ័ពដ៏ធំនិងពោរពេញដោយថាមពលនៅលើកោះនោះ។ រដ្ឋាភិបាលអាមេរិកបាននឹងកំពុងផ្តល់ជំនួយដល់បរទេស និងបានបោះទីតាំងកងទ័ពនៅលើកោះនោះអស់រយៈពេលជាច្រើនឆ្នាំ។ បច្ចុប្បន្ននេះ ដោយមានសម្ពាធរបស់សេអ៊ីអា មានការប្រើឥទ្ធិពលលើមន្ត្រីនានាឲ្យកាត់បន្ថយវិនិយោគទុនបរទេសនៅក្នុងកោះតៃវ៉ាន់នោះ។ ដោយសារតែលុយអាមេរិកបានហូរចូលដោយសេរីទៅក្នុងរដ្ឋនេះ មានវិនិយោគទុននៅគ្រប់ឧស្សាហកម្មផ្នែកផលិតនិងផ្នែកកាត់ដេរទាំងអស់។ បច្ចុប្បន្ននេះ ឧស្សាហកម្មនាំចេញរបស់តៃវ៉ាន់ភាគច្រើន គឺជាកម្មសិទ្ធិ ឬត្រូវបានគ្រប់គ្រងដោយផលប្រយោជន៍អាមេរិក។ ពួកអាមេរិកដែលបានរាំងស្ទះមិនឲ្យមានការរីកចម្រើននេះ បានអនុញ្ញាតឲ្យសេអ៊ីអាធ្វើប្រតិបត្តិការដោយសេរីនៅក្នុងប្រទេសនេះ ដោយបង្កើតនូវការឃោសនាប្រឆាំងនឹងលិទ្ធិកុម្មុយនីស្ត ក៏ដូចជាអនុញ្ញាតឲ្យមានសាជីវកម្មដ៏ធំរបស់អាមេរិកដែលមានច្រើនសញ្ជាតិ ដូចដែលបានលើកឡើងនៅក្នុងគោលនយោបាយរដ្ឋាភិបាល និងយកផលចំណេញទាំងអស់ពីប្រជាជនតៃវ៉ាន់ ហើយបញ្ជូនពួកគេទៅអាមេរិក។ នៅពេលនោះ សកម្មភាពរបស់សេអ៊ីអារយៈពេល ២៨ឆ្នាំ នៅកោះតៃវ៉ាន់បានធ្វើឲ្យប្រជាជនតៃវ៉ាន់ក្លាយជាផលិតករដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រជាជនអាមេរិក ក៏ដូចជាធ្វើឲ្យកោះតៃវ៉ាន់ក្លាយជាអាយ៉ងនយោបាយ និងជាបន្ទាយសម្រាប់...

អ្នកឈ្លបយកការណ៍ចំនួន ១៨០នាក់ ក្នុងចំណោមអ្នកឈ្លបយកការណ៍ចំនួន ២៥០នាក់ នឹងចូលមកពីកោះដែលមានទីតាំងស្ថិតនៅឆ្នេរភាគនិរតីនៃប្រទេសកម្ពុជា។ ក្រោយមកទៀត ពួកគេត្រូវបានឧបត្ថម្ភនូវអាវុធយុទ្ធភ័ណ្ឌ វិទ្យុទាក់ទង ជាដើម ពីទីតាំងនេះ។ ជាលទ្ធផល ទីតាំងនេះនឹងក្លាយជាទីកន្លែងលាក់ខ្លួនដ៏សមស្របនិងយ៉ាងមានសុវត្ថិភាព។ ទីកន្លែងនេះនឹងត្រូវបានសាងសង់ឡើងនៅលើ

កោះមួយដែលត្រូវគេបោះបង់ចោល។ ជាការចាប់ផ្តើម នាវាមុជទឹកអាមេរិកមួយដែលដឹកវិស្វករកងទ័ព និងអ្នកជំនាញការសាងសង់មួយក្រុមនឹងចូលចតដើម្បីសាងសង់ទីជម្រកដែលចាំបាច់។ ទីជម្រកទាំងនេះនឹងត្រូវបានជីកចូលទៅក្នុងដី ហើយនឹងត្រូវធ្វើឲ្យមានពណ៌ដូចប៉ារ៉ាបន្តិនឹងស្លឹកឈើ ។ នឹងមានការតម្លើងម៉ាស៊ីនភ្លើងតូចមួយ និងគ្រឿងបញ្ជូនសារទាក់ទង ទីកន្លែងចម្អិនម្ហូបអាហារ និងរស់នៅសម្រាប់មនុស្សម្នាក់ៗក៏នឹងត្រូវបានផ្តល់ជូនផងដែរ ដោយសារតែវានឹងត្រូវឡើងធ្វើជាអចិន្ត្រៃយ៍ នៅពេលណាដែលប្រតិបត្តិការ "សេះបង្កង់" បានចាប់ផ្តើម។ អូប័រកៅស៊ូតូចមួយដែលត្រូវបំប៉ោងដោយខ្យល់ដែលមានកម្លាំងម៉ូទ័រ ៧០សេះ នឹងត្រូវផ្តល់ឲ្យជាការឧបត្ថម្ភនូវសេវាកម្មឆាប់រហ័ស និងមានប្រសិទ្ធិភាពដល់ទ្វីបនេះ។ នៅពេលណាដែលប្រតិបត្តិការ "សេះបង្កង់" ស្ថិតនៅដំណាក់កាលដែលមានសេចក្តីត្រូវការអាវុធយុទ្ធភ័ណ្ឌ ពេលនោះនាវាមុជទឹកនឹងចាប់ផ្តើមអំពាវនាវសុំឧបករណ៍ចាំបាច់ទាំងអស់ជាទៀងទាត់នៅឯកោះ។ ទូកដែលមានល្បឿនលឿននិងធំជាងនេះទីពីរនឹងត្រូវបានផ្តល់ឲ្យនៅពេលនេះផងដែរ ដើម្បីប្រើអាវុធទាំងនេះឲ្យបានកាន់តែលឿននិងកាន់តែងាយស្រួល។ វិទ្យុទាក់ទងផ្ញើនិងទទួលពត៌មាន នឹងត្រូវបានប្រើប្រាស់ក្នុងការទាក់ទងជាមួយនឹងការទាក់ទងគ្នាតាមរលកធាតុអាកាសរបស់ក្រុមខ្មាំង ដើម្បីត្រួតពិនិត្យអំពីការដឹកនាំភស្តុភារនិងដឹកនាំទ័ព និងដើម្បីទំនាក់ទំនងនាវាមុជទឹកបានគ្រប់ពេល។

លិទ្ធិកុម្មុយនីស្តត្រូវបានរីករាលដាលយ៉ាងយឺតនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ អស់រយៈពេល ២៥ឆ្នាំ ហើយគិតមកដល់ពេលនេះ រីឯពួកអាមេរិកបានប្រកាន់ជំហរប្រឆាំងនឹងលិទ្ធិកុម្មុយនីស្តនៅក្នុងតំបន់ជាច្រើននៅអាស៊ីអាគ្នេយ៍។ គេបានសម្រេចថា ចាប់ពីពេលនេះតទៅ ជំហររឹងមាំនឹងត្រូវធ្វើប្រឆាំងនឹងលិទ្ធិកុម្មុយនីស្ត។ នៅពេលបច្ចុប្បន្ន ប្រទេសអាមេរិកកំពុងប្រមូលផ្តុំនៅប្រទេសថៃ។ វិធីបញ្ឈប់លិទ្ធិកុម្មុយនីស្តរហូតមកទល់នឹងពេលនេះ គឺធ្វើតាមរយៈការចំណាយជំនួយបរទេសនិងប្រាក់ដុល្លាអាមេរិកក្នុងរូបភាពវិនិយោគទុនពាណិជ្ជកម្មចូលទៅក្នុងប្រទេសមួយ។ ការធ្វើបែបនេះត្រូវបានបង្ហាញថា មិនគ្រប់គ្រាន់នោះទេ ហេតុដូច្នេះ នៅប្រទេសថៃ ប្រទេសអាមេរិកបានខំប្រឹងឧបត្ថម្ភគាំទ្រឲ្យបានខ្លាំងជាងនេះ។

ជាដំបូង សេអ៊ីអាមានបំណងត្រួតត្រាក្នុងប្រទេសថៃឲ្យបានខ្លាំងក្លាតាមដែលអាចធ្វើបាន ការត្រួតត្រានេះមានន័យថាទាំងការគ្រប់គ្រងបណ្តាខេត្ត ក៏ដូចជារដ្ឋាភិបាលថ្នាក់កណ្តាលផងដែរ។ ដោយមាន

គោលបំណងនេះនៅក្នុងចិត្ត សេអ៊ីអាបានបង្កើតការិយាល័យភ្នាក់ងារនៅខេត្តភូកេត ឧប៊ុន ឈៀងម៉ៃ និងក្រុងបាងកក។ សេអ៊ីអាក៏មានបំណងចង់ទទួលជោគជ័យនៅក្នុងពិភពពាណិជ្ជកម្មនិងហិរញ្ញវត្ថុផងដែរ។ ដើម្បីធ្វើឲ្យសម្រេចការងារនេះបាន វានឹងធ្វើតាមរយៈប្រជាជនចិនតាមមូលដ្ឋាន ដោយសារតែប្រជាជនទាំងនោះ គឺជាអ្នកដែលគ្រប់គ្រងពាណិជ្ជកម្មនិងឧស្សាហកម្មខ្នាតធំភាគច្រើននៅប្រទេសថៃ។ ដោយមានទំនាក់ទំនងល្អជាមួយមនុស្សនៅក្នុងផ្នែកទាំងពីរនេះ សេអ៊ីអាសង្ឃឹមថានឹងបានត្រួតត្រាច្រើនទៅលើគោលនយោបាយរបស់រដ្ឋាភិបាល។ រឿងមួយក្នុងចំណោមរឿងដំបូងដែលត្រូវធ្វើ គឺត្រូវផ្តាច់ព្រំប្រទល់ប្រទេសកម្មុយនីស្តនៅជុំវិញប្រទេសថៃឲ្យបានទាំងស្រុង។ កងទ័ពនឹងត្រូវបានបោះទីតាំងនៅតាមព្រំដែន ហើយនឹងមិនមានការទំនាក់ទំនងគ្នានៅតាមព្រំដែនទាំងនោះទេ។

ពួកអាមេរិកសង្ឃឹមថារឿងនេះនឹងពន្យឺតសន្ទុះនៃគំនិតកុម្មុយនីស្តចំពោះប្រជាជនថៃ។ ចន្លោះពេលនេះ ពួកអាមេរិកនឹងធ្វើការឃោសនាច្រើនប្រឆាំងនឹងរបបកុម្មុយនីស្ត។ សាលារៀន និងសាកលវិទ្យាល័យនានា គឺជាទិសដៅដែលត្រូវធ្វើការឃោសនាដំបូងគេ ដោយសារតែយុវជនទាំងនេះអាចបង្កបញ្ហាបាននៅប៉ុន្មានឆ្នាំខាងមុខ។ នឹងមានកម្មវិធីផ្លាស់ប្តូរនិស្សិតទៅរៀននៅអាមេរិក រីឯភាសាអង់គ្លេសនឹងត្រូវបានបង្រៀននៅតាមសាលារៀនទាំងអស់ ដោយប្រើមុខវិជ្ជាមេរៀនរបស់អាមេរិក។

ជាមួយនឹងការដាក់ឲ្យនៅក្រៅច្បាប់សរុបរបស់បក្សកុម្មុយនីស្តណាមួយនោះ សេអ៊ីអាសង្ឃឹមថានឹងចាប់ផ្តើមការងារក្រុមតាមដាន។ ពេលនោះ ក្រុមទាំងនេះទទួលបន្ទុកការងាររបស់សេអ៊ីអាក្នុងការតាមប្រមាញ់ គម្រោងការណ៍សម្ងាត់របស់ពួកកុម្មុយនីស្ត។ ក្រុមតាមដានទាំងនេះនឹងជាពលរដ្ឋថៃឯកជនដែលជ្រើសរើសដោយសេអ៊ីអា។ ពួកគេនឹងជាអ្នកគាំទ្រពួកស្តាំនិយមដែលនឹងបង្កើតប្រព័ន្ធច្បាប់ផ្ទាល់ខ្លួនរបស់ពួកគេ និងយកពត៌មានពីភ្នាក់ងារតាមមូលដ្ឋានរបស់សេអ៊ីអា និងពីប្រភពផ្ទាល់របស់ពួកគេ។ រឿងនោះគឺពួកគេនឹងជាផ្នែកដ៏រឹងមាំរបស់សេអ៊ីអា។ កម្មវិធីជំនួយបរទេសអាមេរិកនឹងប្តូរទៅកាន់ប្រទេសថៃវិញ ហើយជាមួយគ្នានេះ ចំនួននិងប្រភេទនៃអាវុធយុទ្ធភ័ណ្ឌនឹងត្រូវផ្គត់ផ្គង់នៅក្នុងផ្នែកជំនួយបរទេស និងការលែងហាមប្រាមទៅលើប្រព័ន្ធនៃការរកឃើញប្រកបដោយបទពិសោធន៍ខ្ពស់បន្ថែមទៀត។ រដ្ឋាភិបាលអាមេរិកនឹងផ្តល់ឲ្យរដ្ឋាភិបាលថៃនូវកម្ចីផ្នែកហិរញ្ញវត្ថុដ៏ច្រើន ដែលនេះជាការធ្វើហិរញ្ញប្បទានកែលម្អកងកម្លាំងប្រដាប់អាវុធថៃ។ នៅពេលដំណាលគ្នានេះ សេអ៊ីអានឹងធ្វើការបញ្ជ្រាបចូលទៅក្នុងកងទ័ពថៃនេះ។ ពួកគេនឹងជ្រើសរើសភ្នាក់ងារមកពីឋានន្តរសក្តិ

ទាប និងស្ទូកប៉ាន់ ឬក៏គម្រាមនាយទាហាននានា ប្រសិនបើពួកគេមិនត្រូវបានជ្រើសរើសយកទេ។ ពេលនោះ ក្រៅពីផ្គត់ផ្គង់អាវុធ យ៉ាងហោចណាស់ពួកអាមេរិកពិតជានឹងមានការត្រួតពិនិត្យទៅលើផ្នែកខ្លះនៃការប្រើប្រាស់អាវុធទាំងនោះ។

ហេតុដូច្នេះហើយ ដោយមានឥទ្ធិពលនៅក្នុងរដ្ឋាភិបាល ក្នុងពាណិជ្ជកម្ម និងក្នុងជួរកងទ័ព សេអ៊ីអាសង្ឃឹមថានឹងអនុវត្តផែនការរបស់ខ្លួនដើម្បីការពារការរីករាលដាលនៃលិទ្ធិកុម្មុយនីស្ត។ វិធីសាស្ត្រផ្ទាល់ខ្លាំងជាងដែលសេអ៊ីអាបានគិតនេះ នឹងផ្តល់នូវលទ្ធផលល្អប្រសើរជាងផែនការផ្តល់ជំនួយសេដ្ឋកិច្ចធម្មតាកាលពីមុន។